

ប្រសិនបើអ្នកជឿជាក់ថា អ្នកបានជួបប្រទះនឹងការរើសអើង ពីដើមកំណើតជាតិសាសន៍ រឺចង់បានពត៌មានបន្ថែម សូមទាក់ទង:

អ្នកក៏អាចនិយាយជាមួយអ្នកគ្រប់គ្រង អំពីមនុស្សដែលអ្នកគិតថាមានការរើសអើងចំពោះអ្នក។ អ្នកក៏អាចនិយាយផងដែរ ជាមួយក្រុមសហគមន៍មួយដែលធ្វើការលើបញ្ហាសិទ្ធិស៊ីវិល។

រួមគ្នា យើងអាចជួយមនុស្សអោយទទួលអត្ថប្រយោជន៍ និងសេវាផ្សេងៗដែលពួកគេត្រូវការ នៅក្នុងរបៀបផ្សេងៗដែលពួកគេអាចយល់បាន។

ឧបត្ថម្ភដោយក្រសួងកសិកម្មសហរដ្ឋអាមេរិក
ក្រសួងសុខាភិបាលនិងសេវាមនុស្សសហរដ្ឋអាមេរិក
និង ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។

**Cambodian - ភាសាខ្មែរ**

# ដឹងពីសិទ្ធិរបស់អ្នក

ក្រុមធ្វើការងារនៃ
អន្តរទីភ្នាក់ងារសហព័ន្ធ
លើភាពចេះភាសាអង់គ្លេសមានកំណត់

តើអ្នកមានបញ្ហាជាមួយភាសាអង់គ្លេសដែររឺទេ? តើអ្នកមិនអាចអាន សរសេរ រឺយល់ភាសាអង់គ្លេសបានល្អទេរឺ? ប្រសិនបើដូច្នោះ អ្នកគឺជាអ្នកចេះភាសាអង់គ្លេសនៅមានកំណត់ **[Limited English Proficient (LEP)]**។

ទីភ្នាក់ងារសហព័ន្ធ និង អង្គការនានា ដែលទទួលលុយពីរដ្ឋាភិបាលសហព័ន្ធ ត្រូវតែចាត់វិធានការណ៍ សមស្រប ដើម្បីជួយប្រជាពលរដ្ឋដែលមានបញ្ហា ផ្នែកភាសាអង់គ្លេស។

ជួនកាល នៅពេលដែលទីភ្នាក់ងាររដ្ឋាភិបាលមួយ រឺ អង្គការមួយមិនជួយអ្នកដោយសារតែអ្នកជា **LEP** គេល្មើសនឹងច្បាប់ហើយ។ ការនេះត្រូវបានគេអោយឈ្មោះថាការរើសអើងពីដើមកំណើតជាតិសាសន៍។

# បើអ្នកត្រូវបានគេប្រព្រឹត្តមិនត្រឹមត្រូវ ពីព្រោះអ្នកជា LEP នោះវាប្រហែលជាការរើសអើងដើមកំណើតហើយ។



មានទូវច្បាប់សហព័ន្ធមួយ ដែលការពារទូវសិទ្ធិស៊ីវិល របស់អ្អក។ ច្បាប់នោះត្រូវបានអោយឈ្មោះថា ***"Title VI"*** នៃច្បាប់សិទ្ធិស៊ីវិលនៃឆ្នាំ ***1964.***

## ឧទាហរណ៍នៃការរើសអើងដែលអាចមាន:

**1** អអ្នក និងមនុស្សជាច្រើន ដែលរស់នៅក្នុងតំបន់របស់អ្នក និយាយភាសាខ្មែរ ហើយក៏ទៅមន្ទីរពេទ្យជាញឹកញយសំរាប់ការព្យាបាលជាអាសន្ន។ មន្ទីរពេទ្យមិនយល់អ្នកជំងឺ **LEP** ទាំងនោះឡើយ។ ភាគច្រើននៃអ្នកជំងឺជាជនជាតិខ្មែរ មិនយល់ពីអ្វីដែលមន្ទីរពេទ្យប្រាប់គេអំពីការថៃទាំសុខភាពរបស់គេទេ។

**2** អ្នក ទូរស័ព្ទទៅលេខ **911** ដើម្បីរាយការណ៍ពីបទឧក្រិដ្ឋមួយ។ អ្នកដែលទទួលទូរស័ព្ទ មិនយល់ពីអ្នក ហើយមិនអាចជួយអ្នក បាន។

**3** សាលារៀនរបស់កូនរបស់អ្នកផ្ញើរនូវពត៌មាន វីសេចក្តីជូនដំណឹងមួយដល់អ្នកជាភាសាអង់គ្លេស។ សាលា ដឹងថាអ្នកនិយាយតែភាសាអេស្ប៉ាញ៉ុលប៉ុណ្ណោះ។ សាលាបដិសេធមិនព្រមផ្តល់ពត៌មានដល់អ្នកជាភាសាអេស្ប៉ាញ៉ុល ហើយផ្ទុយទៅវិញ ស្នើរអោយកូនរបស់អ្នកបកប្រែពត៌មាននោះអោយអ្នក។

**4** អ្នក ព្យាយាមដាក់ពាក្យសុំហ្វូតស្តែម។ ពាក្យសុំនោះ សរសេរជាភាសាអង់គ្លេស។ អ្នកមិនយល់ពីពាក្យសុំនោះទេ។ បុគ្គលិកការិយាល័យហ្វូតស្តែម ប្រាប់អ្នកអោយត្រឡប់មកវិញម្តងទៀតដោយនាំអ្នកបកប្រែដោយផ្ទាល់ខ្លួនរបស់អ្នកមកជាមួយ។

## ឧទាហរណ៍នៃការអនុវត្តន៍ល្អ:

**1** មន្ទីរពេទ្យដឹងថាមានមនុស្សច្រើនណាស់ ដែលមិនអាច យល់ភាសាអង់គ្លេស ហើយនិយាយភាសាខ្មែរ ដែលរស់នៅក្នុងតំបន់របស់អ្នក។ មន្ទីរពេទ្យមានអ្នកបកប្រែដែលប្រុងខ្លួចជាស្រេច ហើយអាចជួយអ្នកបាន នៅពេលអ្នកទៅមន្ទីរពេទ្យ សំរាប់ការថៃទាំព្យាបាលនៅពេលអាសន្ន។

**2** អ្នក ទូរស័ព្ទទៅ **911** ដើម្បីរាយការណ៍ពីបទឧក្រិដ្ឋមួយ។ អ្នកដែលទទួលទូរស័ព្ទ ភ្ជាប់អ្នកភ្លាមទៅកាន់អ្នកបកប្រែដែល អាចជួយអ្នកបាន។

**3** សាសារៀនរបស់កូនរបស់អ្នកមានឪពុកម្តាយនិយាយភាសាអេស្ប៉ាញ៉ុលជាច្រើននាក់។ សាលាដឹងថាអ្នក និយាយបានតែភាសាអេស្ប៉ាញ៉ុលតែប៉ុណ្ណោះ។ អ្នកគួរ តែទទួលពត៌មានសំខាន់ៗ វី សេចក្តីជូនដំណឹងជា ភាសាអេស្ប៉ាញ៉ុល។

**4** ការិយាល័យហ្វូតស្តែម មានអ្នកបកប្រែ វីទាក់ទងអ្នកបកប្រែតាមទូរស័ព្ទអោយជួយអ្នក។ ពាក្យសុំជាភាសារបស់អ្នកត្រូវបានផ្តល់អោយអ្នក។